Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

ជំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបាន ការទុកចិត្ត ចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿ ទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្ត ជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូតលាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុង បន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើន ប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះ ធនាគាររយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាព ដែលមានគុណវុធិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**"

ប្រធានផ្នែកប្តូររូបិយប័ណ្ណ និងផលិតផលរតនាភិបាល (០១ នាក់ បម្រើការងារនៅភ្នំពេញ)

មុខងារនេះស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ របស់នាយក-នាយិកានាយកដ្ឋានរតនាភិបាល ដោយមានមានការតួនាទី និងភារកិច្ចរួម ធ្វើផែនការ និងលក់ផលិតផលរតនាភិបាលកើនឡើងជាប្រចាំឆ្នាំ កំណត់អត្រាប្តូររូបិយប័ណ្ណ សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ របស់ធនាគារ FTB ប្រកបដោយការប្រកួតប្រជែង ។

ការទទួលខុសត្រូវចម្បងៗ

- ចាត់ចែង គ្រប់គ្រង ការលក់ផលិតផលរតនាភិបាល និងធ្វើផែនការលក់កើនឡើងជាប្រចាំឆ្នាំនីមួយៗ ។
- ចាត់ចែង គ្រប់គ្រង និងធ្វើការលក់ផលិតផលរតនាភិបាល (FX, SWAP...) តាមគ្រប់មធ្យោបាយ ដោយផ្ទាល់ជាមួយស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត (Inter-bank) និងប្រយោល ធានារកប្រាក់ចំណូលទៅតាមផែនការបានកំណត់ប្រចាំឆ្នាំ ។
- ចាត់ចែង រៀបចំកំណត់អត្រាប្តូររូបិយប័ណ្ណ សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ របស់ធនាគារ FTB ឱ្យបានត្រឹមត្រូវច្បាស់លាស់ និងទាន់ពេលវេលា ។
- ចាត់ចែង សិក្សាស្រាវជ្រាវប្រចាំថ្ងៃ ពីអត្រាប្តូររូបិយប័ណ្ណនៅលើទីផ្សារក្នុងស្រុក ឬគូប្រកួតប្រជែង និងតាមដានពី បម្រែបម្រួលអត្រាប្តូររូបិយប័ណ្ណបរទេស ដើម្បីជាមូលដ្ឋានក្នុងការកំណត់អត្រាប្តូររូបិយប័ណ្ណ សម្រាប់ប្រតិបត្តិការរបស់ធនាគារ FTB ប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាពខ្ពស់ ។
- ចាត់ចែង ត្រួតពិនិត្យ ផ្តល់ការគាំទ្រដល់គ្រប់សាខាធនាគារ FTB ពីប្រតិបត្តិការប្តូររូបិយប័ណ្ណ ផ្តល់ព័ត៌មានទាន់ហេតុការណ៍ពីបម្រែបម្រួលអត្រាប្តូររូបិយប័ណ្ណ ការចរចាផ្តល់អត្រាប្តូររូបិយប័ណ្ណពិសេស ឬដំណោះស្រាយផ្សេងៗ ឱ្យបានច្បាស់លាស់ ទាន់ពេល និងតាមតម្រូវការពេញចិត្តរបស់អតិថិជន ។
- ចាត់ចែង សរសេរសេចក្តីណែនាំ ជូនដំណឹងដល់សាខាធនាគារ FTB ឬនីតិវិធីពាក់ព័ន្ធនឹងការលក់ផលិតផលរតនាភិបាល ឱ្យបានត្រឹមត្រូវច្បាស់លាស់ សម្រាប់ការអនុវត្តកាន់តែរលូន ។
- ការងារផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់គ្រប់គ្រង ។

ជំនាញ និងបទពិសោធន៍

- បរិញ្ញបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ សេដ្ឋកិច្ច ឬផ្នែកនានាដែលពាក់ព័ន្ធ ឬអនុបណ្ឌិតកាន់តែប្រសើរ
- មានបទពិសោធន៍យ៉ាងតិច ៣ឆ្នាំ ផ្នែករតនាភិបាល ក្នុងវិស័យធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ
- មានជំនាញក្នុងការរៀបចំ ដឹកនាំ ចាត់ចែង និងគ្រប់គ្រងពេលវេលាបានល្អ
- មានភាពអត់ធ្មត់ មានការទទួលខុសត្រូវខ្ពស់ និងមានការយកចិត្តទុកដាក់ក្នុងការងារ
- មានចំណង់ចំណូលចិត្តខ្ពស់ក្នុងការធ្វើការងារជាក្រុម និងអាចដោះស្រាយបញ្ហាបានល្អ
- មានចំណេះដឹងខាងហានិភ័យប្រតិបត្តិការ គោលការណ៍ និងនីតិវិធី
- មានជំនាញទំនាក់ទំនង និងកសាងទំនាក់ទំនងល្អទាំងក្នុង និងក្រៅស្ថាប័ន
- មានចំណេះដឹងភាសាអង់គ្លេស និងអាចប្រើប្រាស់កុំព្យូទ័របានស្ទាត់ជំនាញ (Microsoft Office Word & Excel)

របៀបដាក់ពាក្យ

កាលបរិច្ឆេទកំណត់ដាក់ពាក្យ: ផុតកំណត់ឈប់ទទួលពាក្យនៅថ្ងៃទី **១៥** ខែ **មីនា** ឆ្នាំ **២០២១** វេលាម៉ោង ០៥:០០ រសៀល ។ បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (<u>មានបិទរូបថត ៤x6</u>) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈអ៊ីម៉ែល: hr@ftbbank.com ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។ មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរស័ព្ទអញ្ជើញឲ្យមកចូលសម្ភាសន៍ ។
ពត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទ: ០៨១ ៦៦៦ ៥៩៧/០៨១ ៦៦៦ ៥៣៥

☎ : 023 862 111
E-mail: hr@ftbbank.com
www.ftbbank.com
: www.facebook.com/ftbcambodia